00611206

D337/10/4

# សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី
## មេធាវី ពេជ អង្គ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១០

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 09 / 2010
ម៉ោង (Time/Heure) : 15 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SAMN RADA

**គោរពជូន៖** អង្គបុរេជំនុំជម្រះ
លោកសហចៅក្រមស៊ើបអង្កេត
ភាគីទាំងអស់នៃសំនុំរឿង០០២
ការិយាល័យរដ្ឋបាល(O/DOA, CMS, VSS, DSS)

**ដាក់ជូនដោយ:** សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវី **ពេជ អង្គ**

**កម្មវត្ថុ៖** ស្តីពីការដកខ្លួនពីការតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២។

**យោង៖** លិខិតចាត់តាំងសហមេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១០ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតជំរាបជូន លោក លោកស្រី ប្រធាន និងចៅក្រមនៃអង្គបុរេជំនុំជម្រះ មេត្តាជ្រាបថាខ្ញុំបាទត្រូវបានចាត់តាំងជាសហមេធាវីនាំមុខជាតិដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១០ និងត្រូវចូលកាន់តួនាទីចាប់ពីថ្ងៃ ០១ ខែតុលា ឆ្នាំ ២០១០ទៅ។ ដោយឡែកបច្ចុប្បន្ននេះ ខ្ញុំបាទស្ថិតនៅជាមួយលោកស្រីមេធាវី ជេត វណ្ណលី និងលោកមេធាវី វ៉ែន ពៅ ក្នុងក្រុមមេធាវីទទួលមូនិធិពីតុលាការដែលតំណាងរួមឲ្យកូនក្តីដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ចំនួន១២៣៩ នាក់។ ដូច្នោះ ដើម្បីឲ្យខ្ញុំបាទអាចបំពេញតួនាទីជាសហមេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានទំនាស់ផលប្រយោជន៍ ខ្ញុំបាទសូមដកខ្លួនចេញពីការតំណាងកូនក្តីនៅក្នុងក្រុមដូចបានជម្រាបជូនខាងលើ ចាប់ពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១០ នេះតទៅ។ ក្រោយពីការដកខ្លួនរបស់ខ្ញុំបាទ កូនក្តីទាំងអស់នៅតែបន្តតំណាងរួមគ្នាដោយសហភាតាទាំងពីររបស់ខ្ញុំ។

សេចក្តីដូចបានជម្រាបជូនខាងលើសូម អង្គបុរេជំនុំជម្រះ មេត្តាទទួលជ្រាបដោយអនុគ្រោះ។

ដោយក្តីគោរព។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ហត្ថលេខា

**មេធាវី ពេជ អង្គ**